00161550

**Declassified to Public**
**06 September 2012**

A54/I

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 08 / FEB / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: NUP SOTHUNVICHET

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 08 / FEB / 2008
ម៉ោង (Time/Heure): 14:20'
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: NUP SOTHUNVICHET

## ការិយាល័យសហចៅក្រមស៊ើបអង្កេត

## អនុសារណៈផ្ទៃក្នុង

**ជូនចំពោះ៖** លោកប្រធានមន្ទីរឃុំឃាំងរបស់អង្គជំនុំជម្រះវិសាមញ្ញ ថ្ងៃទី ០៨ កុម្ភៈ ២០០៨

**យោង ៖** លិខិតស្នើសុំរបស់មេធាវីរបស់លោក កាំង ហ្គេកអ៊ាវ ហៅឌុច ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០០៧

**ពី ៖** លោក យូ ប៊ុនឡេង

លោក Marcel LEMONDE

សហចៅក្រមស៊ើបអង្កេត

**កម្មវត្ថុ** ការអនុញ្ញាត្តិអោយមេធាវីរបស់លោកកាំង ហ្គេកអ៊ាវ ចូលជួបកូនក្តីដោយនាំយកទៅផ្តល់ឱ្យនូវឯកសារដែលមាននៅក្នុងសំណុំរឿង

តាមរយៈលិខិតចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៧ មេធាវីរបស់ជនត្រូវចោទ បានស្នើសុំការអនុញ្ញាតផ្តល់នូវឯកសារមួយចំនួននៃសំណុំរឿងទៅដល់ជនជាប់ឃុំ កាំង ហ្គេកអ៊ាវ ដើម្បីធ្វើការពិនិត្យពិគ្រោះ ។

ដោយពិចារណាដល់ទំហំ និង ភាពស្មុគ្រស្មាញនៃរឿងក្តី និង ដើម្បីធានាការគោរពសិទ្ធិការពារខ្លួនរបស់ជនត្រូវចោទអោយកាន់តែមានប្រសិទ្ធិភាព យើង សម្រេចអនុញ្ញាតអោយមេធាវី ឬ អ្នកតំណាងរបស់មេធាវីរបស់ជនត្រូវចោទ កាំង ហ្គេកអ៊ាវ ចូលជួបជននេះ ដោយយកទៅជាមួយនូវឯកសារខ្លះនៃសំណុំរឿងដែលអាចប្រគល់ទៅអោយជនជាប់ឃុំបាន ប៉ុន្តែ ត្រូវគោរពលក្ខខណ្ឌពីរបន្ថែមលើលក្ខខណ្ឌផ្សេងៗទៀតដែលមន្ទីរឃុំឃាំង តម្រូវ ៖

១- មេធាវី ឬ អ្នកតំណាងរបស់មេធាវី ត្រូវផ្តល់ឯកសារទាំងនោះទៅឱ្យជនត្រូវចោទដោយខ្លួនឯងផ្ទាល់។ និង

២- ឯកសារសំណុំរឿងទាំងនោះ ត្រូវប្រគល់មកឱ្យមេធាវី ឬ អ្នកតំណាងរបស់មេធាវីនោះវិញ ដោយជនជាប់ឃុំ រៀងរាល់ថ្ងៃ នៅពេលបញ្ចប់ការពិនិត្យពិគ្រោះឯកសារម្តងៗ និង មិនអាចរក្សាទុកដោយជននេះបានឡើយ។

អាស្រ័យហេតុដូចនេះសូមលោកប្រធានជួយសម្រួលក្នុងកិច្ចការនេះ តាមលក្ខខណ្ឌដែលបានកំណត់នៅក្នុងអនុសារណៈនេះ។